# ការបញ្ចេញមតិច្នៃប្រឌិតក្នុងចំណោមមនុស្សវ័យក្មេងកម្ពុជា

## សិក្ខាសាលាអនឡាន៖ ថ្ងៃទី ២៧-២៨ ខែឧសភា ឆ្នាំ២០២១

ថ្ងៃព្រហស្បតិ៍ ទី ២៧
២:០០ រសៀល ៖ ការបង្កើតសិល្បៈសហសម័យ និងការបញ្ចេញមតិប្រកបដោយភាពច្នៃប្រឌិតនៅក្នុងគោលនយោបាយជាតិស្តីពីវប្បធម៌ នៃប្រទេសកម្ពុជា



ការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា សិល្បករវ័យក្មេងមើលឃើញនូវតួនាទីយុទ្ធសាស្ត្រសម្រាប់រាជរដ្ឋាភិបាល ក្នុងកិច្ចអភិវឌ្ឍន៍វិស័យសិល្បៈនៅកម្ពុជា។ ពួកគេមានបំណងយ៉ាងមុតមាំក្នុងការធ្វើការជាមួយ រាជរដ្ឋាភិបាលក្នុងផ្នែកគោលនយោបាយ បើទោះបីជាចំណេះដឹងទាក់ទងនឹងគោលនយោបាយរបស់ ពួកគេនៅមានកម្រិតក៏ដោយ។ ការស្រាវជ្រាវនេះក៏រកឃើញផងដែរនូវឱកាសពង្រីកវិសាលភាពគោលនយោបាយវប្បធម៌ ដូចជាការផ្លាស់ប្តូរវប្បធម៌អន្តរជាតិ និងការអប់រំសិល្បៈ ដែលអាចបម្រើកិច្ចអភិវឌ្ឍន៍សម្រាប់វិស័យសិល្បៈ។ ជាមួយនឹងគំហើញទាំងនេះ សិក្ខាសាលាទី១ នឹងផ្តោតលើសំណួរដូចជា៖

- តើមានគោលការណ៍អ្វីខ្លះដែលគោលនយោបាយជាតិវប្បធម៌របស់កម្ពុជាបានបង្កឱកាសដល់ការបង្កើតសិល្បៈសហសម័យ និងការបញ្ចេញមតិប្រកបដោយភាពច្នៃប្រឌិត?
- តើសិល្បករអាចចូលរួមជាមួយក្រុមអ្នកបង្កើតគោលនយោបាយ ដើម្បីចែករំលែកគំនិត និង ក្តីបារម្ភរបស់ពួកគេបានយ៉ាងដូចម្តេចខ្លះ?
- តើមានគោលនយោបាយអ្វីខ្លះ ដែលផ្តល់ការគាំទ្រដល់មនុស្សវ័យក្មេងដើម្បីរៀនសូត្រ និង អបអរសិល្បៈសហសម័យ?
- តើមានក្តីកង្វល់អ្វីខ្លះ ចំពោះការបង្កបរិយាកាសឲ្យមានការបញ្ចេញមតិបែបច្នៃប្រឌិត និងការបង្កើតសិល្បៈសហសម័យក្នុងចំណោមមនុស្សវ័យក្មេង?

៣:៣០ រសៀល ៖ សម្រាក
អំឡុងពេលសម្រាកនេះ យើងនឹងចាក់បញ្ចាំងការសម្តែង «កន្លោង» ដោយៈ សុខ ណាលី ជាអ្នកដំឡើងស្នាដៃនេះសម្រាប់កម្មវិធីរដូវវប្បធម៌ ឆ្នាំ ២០២០ ដោយអង្គការសិល្បៈខ្មែរអមតៈ។

### ៣:៥០ រសៀល ៖ លទ្ធផលស្រាវជ្រាវ ៖ ការបង្កើតសិល្បៈសហសម័យ និង ការបញ្ចេញមតិប្រកបដោយភាពច្នៃប្រឌិតក្នុងចំណោមមនុស្សវ័យក្មេងកម្ពុជា

លោកស្រីបណ្ឌិត អាម៉ានដា រ៉ូថឺ និង លោក យាន រស្មី នឹងធ្វើបទបង្ហាញស្តីពីរបាយការណ៍នៃគម្រោងស្រាវជ្រាវ និងលទ្ធផលចេញពីការស្រាវជ្រាវនេះ។ របាយការណ៍នេះផ្តោតលើសំណួរមួយចំនួនដូចជា៖

- ការរំពឹងទុករបស់សិល្បករវ័យក្មេងទៅលើកេរដំណែលនៃរបបខ្មែរក្រហម ប្រពៃណីបន្តសហសម័យ ផ្នត់គំនិតដែលជឿថាសិល្បៈ ជាកញ្ចក់ឆ្លុះបញ្ចាំងពីសង្គម និង អត្តសញ្ញាណ
- តើទស្សនិកជនវ័យក្មេងគឺជានរណា? តើពួកគាត់ទទួលបានអ្វីខ្លះពីសិល្បៈសហសម័យនាពេលបច្ចុប្បន្ន? តើពួកគេចង់បានអ្វីខ្លះពីសិល្បៈ ដើម្បីអនាគត?

បន្ទាប់ពីបទបង្ហាញខ្លី កម្មវិធីនឹងបើកឲ្យមានកិច្ចសន្ទនា សំណួរ និងចម្លើយពីអ្នកចូលរួម។

### ៥:០០ ល្ងាច ៖ ចប់ថ្ងៃទី១

### ថ្ងៃសុក្រ ទី ២៨

### ២:០០ រសៀល ៖ តើសិល្បៈគឺសម្រាប់នរណា?

តាមអ្វីដែលយើងខ្ញុំសង្កេត របាយការណ៍ស្រាវជ្រាវនេះជាការស្រាវជ្រាវធំដំបូងគេមួយនៅកម្ពុជា ដែលបានសិក្សាស្រាវជ្រាវអំពីទស្សនិកជនសិល្បៈ។ វាផ្តល់នូវការយល់ឃើញថ្មី អំពីនរណាខ្លះចូលរួមក្នុងសកម្មភាពសិល្បៈ និងតើអ្វីជាកត្តាជម្រុញឲ្យពួកគេចូលរួមក្នុងសិល្បៈ។ វាជួយបង្កើតឱ្យមានសំណួរ ជាពិសេសសម្រាប់សិល្បករ និងអ្នករៀបចំកម្មវិធីសិល្បៈថាតើ សិល្បៈណាត្រូវបានបង្កើតដើម្បីនរណា? ចែករំលែកជាមួយអ្នកណា? និងថា បំណងប្រាថ្នា និងសមត្ថភាពខុសគ្នារវាងអ្នកបង្កើតស្នាដៃ ផលិតករ និងទស្សនិកជន។ វាក្រឡេកមើលសិល្បៈនៅក្នុងបរិបទនៃចំណាប់អារម្មណ៍ និងកង្វល់ដទៃទៀតក្នុង ចំណោមមនុស្សវ័យក្មេងនៅភ្នំពេញសព្វថ្ងៃ។

ក្នុងវេទិកាពិភាក្សានេះ វាគ្មិននឹងពិភាក្សាសំណួរនានា ដោយបញ្ចូលនូវប្រភេទផ្សេងគ្នានៃយុវជន ដែលចូលរួមក្នុងសិល្បៈ លទ្ធភាពនានាសម្រាប់មាតិកា កម្សាន្ត និងសង្គម និងវេទិកាដែលសិល្បៈត្រូវបានបង្ហាញ និងថាតើការបង្ហាញសិល្បៈទាំងនោះជះឥទ្ធិពលយ៉ាងណាទៅលើចំណាប់អារម្មណ៍របស់យុវជន។ សូមចូលរួមចែករំលែកគំនិត និងសំណួររបស់អ្នកក្នុងប្រធានបទនេះ។

### ៣:០៥ ៖ វីដេអូរបាំ៖ ធ្វើអោយលេចចេញឡើងជារូបរាងនៃបច្ចុប្បន្នដើម្បីអនាគត

កោសិកា ៖ នៅក្នុងស្នាដៃមួយនេះគឺបង្ហាញអំពីដំណើរជីវិតមនុស្សចាប់កំណើតចេញពីផ្ទៃម្តាយរហូតដល់ស្លាប់។ រឿងរ៉ាវចាប់ផ្តើមពីទារកក្នុងផ្ទៃ រហូតដល់ធំធាត់ ជាជីវិតដែល មានការតស៊ូ សុភមង្គល មហិច្ឆតា និងឧបសគ្គ។ ទាំងអស់នេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈគំនិតនិងការប្រើប្រាស់សម្ភារៈឆ្នៃប្រឌិតផ្សេងៗ របស់កាគូ ជាបទភ្លេងថ្មីដែលទាក់ទងទៅអត្ថន័យសាច់រឿង អមជាមួយក្បាច់រាំរបស់អ្នករាំ ដើម្បីធ្វើឲ្យប្លែកពីអ្វីដែលអ្នកបានឃើញនិងអាចទទួលយកបទពិសោធន៍ ថ្មីពីស្នាដៃមួយនេះ។ អមដោយសំណួរនិងចម្លើយជាមួយសិល្បករ។

សំណួរ និង ចម្លើយជាមួយសិល្បករ

### ៣:៥០ រសៀល ៖ សម្រាក

### ៤:០០ រសៀល ៖ ប្រភពនៃឥទ្ធិពលនិង ការញ៉ាំងចិត្ត?

វគ្គចុងក្រោយនៃសិក្ខាសាលានេះផ្តោតលើចំណុចលម្អិតបន្ថែមទៀត ដែលសិល្បករកម្ពុជារកឃើញប្រភពនានា នៃឥទ្ធិពល និងការញ៉ាំងចិត្តនៅពេលបង្កើតស្នាដៃថ្មី។ ប្រធានបទនេះក៏នឹងពិនិត្យថាតើ ឥទ្ធិពល និងការញ៉ាំងចិត្តនេះ បានផ្លាស់ប្តូរតាមពេលវេលាដែរឬទេ។ ការស្រាវជ្រាវបានរកឃើញថាទោះបីជា សិល្បករជារឿយៗ ជជែកអំពីការស្វែងរកការញ៉ាំងគំនិត ពីជីវិតប្រចាំថ្ងៃ និងព្រឹត្តិការណ៍សង្គមនានា (ទាក់ទងនឹងគំនិតដែលថា «សិល្បៈជាកញ្ចក់ឆ្លុះបញ្ចាំង ដល់សង្គម») ក៏ដោយ ក៏បទពិសោធន៍ផ្ទាល់ខ្លួន និងសិល្បៈកម្ពុជាខ្លួនឯង ក៏ជាឥទ្ធិពលដ៏សំខាន់។ ដូច្នេះវគ្គនេះនឹងផ្តោតលើសំណួរដូចជា៖

- តើសិល្បករស្វែងរកប្រភពនៃការញ៉ាំងចិត្ត នៅពេលបង្កើតស្នាដៃសហសម័យពីណា?
- តើសិល្បៈបែបប្រពៃណីជាប្រភពនៃការញ៉ាំងចិត្តដល់កម្រិតណា?
- តើសិល្បៈ ពិសេសសិល្បៈសហសម័យពិតជាកញ្ចក់ឆ្លុះបញ្ចាំងពីសង្គមមែនឬ?
- តើឌីជីថលមេឌា មានតួនាទីអ្វីក្នុងដំណើរការអស់ទាំងនេះ?

៥:០០ ល្ងាច៖ ចប់កម្មវិធី

CHANGING THE STORY
Swansea University Prifysgol Abertawe
GCRF Global Challenges Research Fund
UKRI
Arts and Humanities Research Council